ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៣១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលការកំណត់ប្រាក់ឧបត្ថម្ភលើកដំបូងម្តងគត់ជូនមន្ត្រីរាជការស៊ីវិល ចៅក្រម និង ព្រះរាជអាជ្ញា ដែលចូលនិវត្តន៍ ចូលបាត់បង់សម្បទាវិជ្ជាជីវៈ មរណភាព សុំលាឈប់ពីការងារ សុំចូលនិវត្តន៍មុនកាលកំណត់ និងមិនគ្រប់លក្ខខណ្ឌចូលនិវត្តន៍ ឬ ចូលបាត់បង់សម្បទាវិជ្ជាជីវៈ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/ នស/ ៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩២ ស្តីពីការកែលំអបៀវត្សកម្មាភិបាល បុគ្គលិក កម្មកររដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តរបបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈចំពោះមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៨០ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០២ ស្តីពីការគ្រប់គ្រងដំណើរការ នៃការដាក់មន្ត្រីរាជការស៊ីវិលឱ្យចូលនិវត្តន៍តាមអាយុ តាមប្រព័ន្ធព័ត៌មានវិទ្យា

www.pheakdeylaw.com

- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០២ ស្តីពីការកែសម្រួលការអនុវត្តរបបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈចំពោះមន្ត្រីរាជការស៊ីវិលតាមប្រព័ន្ធបៀវត្សថ្មី
- អនុក្រឹត្យលេខ ៣២ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០០៩ ស្តីពីការកំណត់ប្រាក់ឧបត្ថម្ភលើកដំបូង និងប្រាក់សោធនជូនចៅក្រម និងព្រះរាជអាជ្ញាដែលត្រូវចូលនិវត្តន៍ ឬ ចូលបាត់បង់សម្បទាវិជ្ជាជីវៈ
- យោងតាមការចាំបាច់

# សម្រេច

## មាត្រា ១-

អនុក្រឹត្យនេះមានគោលដៅកែសម្រួលការកំណត់ប្រាក់ឧបត្ថម្ភលើកដំបូងម្តងគត់ជូនមន្ត្រីរាជការស៊ីវិល មន្ត្រីរាជការដែលមានក្របខ័ណ្ឌមុខងារសាធារណៈទទួលមុខតំណែងនយោបាយ ចៅក្រម និងព្រះរាជអាជ្ញាដែលចូលនិវត្តន៍ ចូលបាត់បង់សម្បទាវិជ្ជាជីវៈ មរណភាព សុំលាឈប់ពីការងារ សុំចូលនិវត្តន៍មុនកាលកំណត់ និងមិនគ្រប់ល័ក្ខខ័ណ្ឌចូលនិវត្តន៍ ឬចូលបាត់បង់សម្បទាវិជ្ជាជីវៈ ។

## មាត្រា ២-

មន្ត្រីរាជការស៊ីវិល មន្ត្រីរាជការដែលមានក្របខ័ណ្ឌមុខងារសាធារណៈទទួលមុខតំណែងនយោបាយ ចៅក្រម និងព្រះរាជអាជ្ញា ដែលចូលនិវត្តន៍ ចូលបាត់បង់សម្បទាវិជ្ជាជីវៈ មរណភាព សុំលាឈប់ពីការងារ សុំចូលនិវត្តន៍មុនកាលកំណត់ និងមិនគ្រប់ល័ក្ខខ័ណ្ឌចូលនិវត្តន៍ ឬ ចូលបាត់បង់សម្បទាវិជ្ជាជីវៈ ត្រូវបានទទួលប្រាក់ឧបត្ថម្ភលើកដំបូងម្តងគត់ ស្មើនឹងប្រាក់បៀវត្សមូលដ្ឋានចុងក្រោយគុណនឹងចំនួនខែ ដូចដែលបានកំណត់ក្នុងមាត្រា ៨ នៃអនុក្រឹត្យលេខ ០៥ អនក្រ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩២ ស្តីពីការកែលំអបៀវត្សកម្មាភិបាល បុគ្គលិក កម្មកររដ្ឋ មាត្រា ៥ . ៦ និង មាត្រា ១៤ នៃអនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តរបបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈចំពោះមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ១ នៃអនុក្រឹត្យលេខ ៣២ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០០៩ ស្តីពីការកំណត់ប្រាក់ឧបត្ថម្ភលើកដំបូង និងប្រាក់សោធនជូនចៅក្រម និងព្រះរាជអាជ្ញាដែលត្រូវចូលនិវត្តន៍ ឬ ចូលបាត់បង់សម្បទាវិជ្ជាជីវៈ ប្រការ ៥ ចំណុច ក២ និងចំណុច ខ២ នៃសេចក្តីសម្រេចលេខ ២៤៥ សសរ. ចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ១៩៨៨ ស្តីពីរបបគោលនយោបាយធានារ៉ាប់រងសង្គមសម្រាប់កម្មាភិបាល បុគ្គលិក កម្មកររដ្ឋ និវត្តជន និងជនបាត់បង់សមត្ថភាពពលកម្ម និងសេចក្តីណែនាំលេខ ០០៨ ស.អ.យ. ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០៨ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីការកំណត់ប្រាក់ឧបត្ថម្ភលើកដំបូង និងប្រាក់សោធនជូនមន្ត្រីរាជការមានក្របខ័ណ្ឌមុខងារសាធារណៈទទួលមុខតំណែងនយោបាយដែលត្រូវចូលនិវត្តន៍ ឬ ចូលបាត់បង់សម្បទាវិជ្ជាជីវៈ ។

## មាត្រា ៣-

អនុក្រឹត្យនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី ០២ ខែ មករា ឆ្នាំ ២០១០ តទៅ ។

## មាត្រា ៤-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

www.pheakdeylaw.com

**មាត្រា ៥-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

ក្រសួងព្រះបរមរាជវាំង
អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋានរដ្ឋសភា
អគ្គលេខាធិការរាជរដ្ឋាភិបាល
ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
ដូចមាត្រា ៥
គ្រប់សាលាខេត្ត-រាជធានី
រាជកិច្ច ✓
ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com